# អព្ភូតហេតុនៃដង្វាយធួន

អែលឌើរ ស៊ី ស្កត ហ្គ្រូ
នៃពួកចិតសិបនាក់

*គ្មានបាប ឬការរំលង ការឈឺចាប់ ឬទុក្ខព្រួយណាមួយដែលមិនអាចទទួលការអភ័យទោសដោយអំណាចព្យាបាលនៃដង្វាយធួនទ្រង់ឡើយ ។*

ពេលរៀបចំការនិយាយរបស់ខ្ញុំសម្រាប់សន្និសីទនេះ ខ្ញុំបានទទួលទូរស័ព្ទដោយមិនបានព្រាងទុកពីឪពុកខ្ញុំ ។ គាត់បាននិយាយថា ប្អូនប្រុសរបស់ខ្ញុំបានស្លាប់ក្នុងដំណេកនាព្រឹកនោះ ។ ខ្ញុំសោកសៅជាខ្លាំង ។ គាត់មានអាយុទើបតែ 51 ឆ្នាំ ។ ពេលខ្ញុំគិតពីគាត់ ។ ខ្ញុំចង់ចែកចាយនូវព្រឹត្តិការណ៍មួយចំនួនក្នុងជីវិតរបស់គាត់ជាមួយនឹងអ្នក ។ ខ្ញុំធ្វើកិច្ចការនេះដោយមានការអនុញ្ញាត ។

កាលពីក្មេង ប្អូនប្រុសខ្ញុំមានរូបរាងសង្ហារ ហើយរាក់ទាក់ស្និទ្ធស្នាល – គឺមានការលះបង់ខ្លាំងចំពោះដំណឹងល្អ ។ ក្រោយពីបញ្ចប់បេសកកម្ម គាត់បានរៀបការនឹងភរិយាគាត់ក្នុងព្រះវិហារបរិសុទ្ធ ។ពួកគេបានប្រទានពរឲ្យមានកូនប្រុសម្នាក់កូនស្រីម្នាក់ ។ អនាគតគាត់គឺពេញដោយសក្ដានុពល ។

តែក្រោយមកគាត់បានចុះខ្សោយ ។ គាត់បានជ្រើសរស់នៅក្នុងជីវិតនៃអ្នកសប្បាយនិយម ដែលធ្វើឲ្យគាត់ខូចសុខភាព បាត់បង់គ្រួសារ និងសមាជិកភាពគាត់ក្នុងសាសនាចក្រ ។

គាត់បានផ្លាស់ទៅរស់នៅឆ្ងាយពីផ្ទះ ។ គាត់បន្តធ្វើទង្វើនេះអស់រយៈពេលជាច្រើនឆ្នាំ តែព្រះអង្គសង្គ្រោះមិនបានបំភ្លេច ឬបោះបង់គាត់ឡើយ ។

ទីបំផុត ភាពអស់សង្ឃឹមរបស់គាត់បានអនុញ្ញាតឲ្យវិញ្ញាណនៃការបន្ទាបខ្លួនជ្រាបចូលក្នុងព្រលឹងគាត់ ។ កំហឹង ការទាស់ប្រឆាំង និងការរុករានរបស់គាត់បានចាប់ផ្ដើមរសាយបាត់ ។ ដូចកូនប្រុសដែលខ្ជះខ្ជាយដែរ « គាត់បានភ្ញាក់ដឹងខ្លួន » ។[1] គាត់បានចាប់ផ្ដើមងាកទៅរកព្រះអង្គសង្គ្រោះ ហើយត្រឡប់មករកដំណឹងល្អវិញ ។

គាត់បានដើរលើផ្លូវនៃការប្រែចិត្ត ។ វាមិនងាយស្រួលឡើយ ។ ក្រោយចេញពីសាសនាចក្ររយៈពេលម្ភៃឆ្នាំ គាត់បានជ្រមុជទឹកជាថ្មី ។ ទីបំផុត បព្វជិតភាពនិងពរជ័យនៃព្រះវិហារបរិសុទ្ធរបស់គាត់ត្រូវបានស្ដារឡើងវិញ ។

គាត់បានទទួលពរដោយរកឃើញនារីម្នាក់ដែលមិនខ្វល់ពីបញ្ហាសុខភាពដែលបណ្ដាលមកពីជីវិតរបស់គាត់ពីមុន ហើយពួកគេបានផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ។ ពួកគេមានកូនពីរនាក់ ។ គាត់បម្រើក្នុងគណៈប៊ីស្សពអស់រយៈពេលជាច្រើនឆ្នាំ ។

ប្អូនប្រុសខ្ញុំស្លាប់នៅព្រឹកថ្ងៃចន្ទ ទី 7 ខែមិនា ។ កាលពីល្ងាចថ្ងៃសុក្រមុននោះ គាត់និងភរិយាបានចូលទៅព្រះវិហារបរិសុទ្ធ ។ នាព្រឹកថ្ងៃអាទិត្យ ពីមុនគាត់ស្លាប់មួយថ្ងៃ គាត់បានបង្រៀនមេរៀនបព្វជិតភាពក្នុងក្រុមសង្ឃជាន់ខ្ពស់ ។ គាត់បានចូលដំណេកនាយប់នោះ ហើយនឹងមិនភ្ញាក់ទៀតឡើយក្នុងជីវិតនេះ --តែនឹងភ្ញាក់ឡើងក្នុងដំណើររស់ឡើងវិញនៃពួកសុចរិត ។

ខ្ញុំមានអំណរចំពោះអព្ភូតហេតុនៃដង្វាយធួនក្នុងជីវិតប្អូនប្រុសខ្ញុំ ។ ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះគឺមានសម្រាប់យើងគ្រប់គ្នាជានិច្ច ។

យើងទទួលបានដង្វាយធួនតាមរយៈការប្រែចិត្ត ។ ពេលយើងប្រែចិត្ត
ព្រះអម្ចាស់អនុញ្ញាតឲ្យយើងទុកកំហុសពីអតីតនៅខាងក្រោយយើង ។

« មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់មិនចាំពីអំពើបាបទាំងនោះទៀតទេ ។

« តាមរបៀបនេះអ្នករាល់គ្នាអាចដឹងបើសិនជាមនុស្សណាម្នាក់ប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួនមែន ឬអត់ ---មើលចុះអ្នកនោះនឹងសារភាពអំពីអំពើបាបទាំងឡាយ ហើយលះបង់ចោលអំពើបាបទាំងនោះ » ។[2]

យើងម្នាក់ៗស្គាល់មនុស្សម្នាក់ដែលមានឧបសគ្គដ៏ធំនៅក្នុងជីវិត ---គឺជាអ្នកដែលបានងឿងឆ្ងល់ ឬច្របូកច្របល់ ។ បុគ្គលនោះអាចជាមិត្តភក្តិ ឬសាច់ញាតិ ជាឪពុក ឬកូន ជាស្វាមី ឬភរិយា ។ បុគ្គលនោះអាចជារូបអ្នកខ្លួនឯងដែរ ។

ខ្ញុំសូមនិយាយទៅមនុស្សគ្រប់គ្នា រួមទាំងអ្នកដែរ ។ ពីអព្ភូតហេតុនៃដង្វាយធួន ។

ព្រះមែស៊ីបានយាងមកប្រោសលោះមនុស្សពីការធ្លាក់នៃអ័ដាម ។[3] អ្វីៗទាំងអស់ក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគឺទាញទៅរកការលះបង់ធ្វើឲ្យធួននៃព្រះមែស៊ី ដែលជាព្រះរាជបុត្រានៃព្រះ ។[4]

ផែនការសង្គ្រោះមិនអាចកើតឡើងដោយគ្មានដង្វាយធួនបានឡើយ ។ « ហេតុដូច្នេះហើយព្រះអង្គទ្រង់ផ្ទាល់បានធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក ដើម្បីនាំមកនូវផែនការនៃសេចក្តីមេត្តាករុណា ដើម្បីធ្វើឲ្យស្កប់ស្កល់ដល់ការទាមទារនៃសេចក្តីយុត្តិធម៌ ដើម្បីព្រះជាព្រះដ៏ល្អឥតខ្ចោះ ហើយត្រឹមត្រូវ និងជាព្រះដែលប្រកបដោយសេចក្តីមេត្តាករុណាផង » ។[5]

ការលះបង់ធ្វើឲ្យធួនត្រូវតែធ្វើឡើងដោយព្រះរាជបុត្រានៃព្រះដែលគ្មានអំពើបាប ត្បិតមនុស្សមិនអាចធួនសម្រាប់បាបខ្លួនឡើយ ។6 ដង្វាយធួនត្រូវតែមានភាពនិរន្តរ និងអស់កល្ប ---ដើម្បីអនុវត្តចំពោះមនុស្សគ្រប់គ្នា និងក្នុងភាពអស់កល្ប ។[7]

តាមរយៈការរងទុក្ខ និងការសុគតរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានធួនសម្រាប់បាបមនុស្សទាំងអស់ ។[8] ដង្វាយធួនទ្រង់ចាប់ផ្តើមក្នុងគេតសាម៉ានី ហើយបន្តនៅលើឈើឆ្កាង ហើយបញ្ចប់ក្នុងការរស់ឡើងវិញ ។

« មែនហើយ ...គង់តែទ្រង់ត្រូវគេដឹក ត្រូវគេឆ្កាង ហើយត្រូវគេធ្វើគុត ឯសាច់ឈាមត្រូវនៅក្រោមអំណាចនៃសេចក្តីស្លាប់ គឺព្រះហឫទ័យនៃព្រះរាជបុត្រាត្រូវលេបដណ្តប់នៅក្នុងព្រះហឫទ័យនៃព្រះវរបិតា »។[9] តាមរយៈការលះបង់ធ្វើឲ្យធួនរបស់ទ្រង់ ទ្រង់បានធ្វើ« ព្រះជន្មរបស់ទ្រង់បានត្រូវថ្វាយទុកជាយញ្ញបូជាលោះបាប » ។[10]
ក្នុងនាមជាព្រះរាជបុត្រាសំណប់តែមួយគត់ ទ្រង់បានគ្រងអំណាចដើម្បីយកឈ្នះលើក្តីស្លាប់ ។ ការណ៍នោះអនុញ្ញាតឲ្យទ្រង់ជួយដល់ព្រះជន្មទ្រង់ ពេលទ្រង់បានរងទុក្ខ « ច្រើនជាងមនុស្សលោកអាចស៊ូទ្រាំបានទៅទៀត លើកលែងតែសេចក្តីស្លាប់ប៉ុណ្ណោះ ត្បិតមើលចុះព្រះលោហិតចេញមកពីគ្រប់រន្ធញើស សេចក្តីបារម្ភរបស់ព្រះអង្គ[ គឺ ]មានឡើងយ៉ាងខ្លាំងចំពោះអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយនៃរាស្ត្ររបស់ទ្រង់ » ។[11]

ទ្រង់មិនគ្រាន់តែបានបង់ថ្លៃសម្រាប់បាបមនុស្សលោកប៉ុណ្ណោះទេ ទ្រង់ក៏« លើកដាក់លើខ្លួនទ្រង់នូវការឈឺចាប់ និងជំងឺទាំងឡាយរបស់រាស្ត្រទ្រង់ » ។[12] ហើយទ្រង់« ដាក់លើរូបអង្គទ្រង់នូវជំងឺឈឺចាប់របស់ពួកគេ ដើម្បីឲ្យព្រះហឫទ័យទ្រង់បានពោរពេញទៅដោយសេចក្តីមេត្តាករុណា ...ដើម្បីទ្រង់អាចដឹងស្របតាមសាច់ឈាមថាតើត្រូវជួយរាស្ត្រទ្រង់បែបណាតាមជំងឺរបស់គេ » ។[13]

ព្រះអង្គសង្គ្រោះយល់ពីទម្ងន់នៃការថប់បារម្ភរបស់មនុស្សលោក ---ជាការថប់បារម្ភនៃអំពើបាប និងទុក្ខព្រួយ ។ « ទ្រង់បានទ្រាំទ្ររងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងជាពិត » ។[14]

តាមរយៈដង្វាយធួនរបស់ទ្រង់ ទ្រង់មិនគ្រាន់តែព្យាបាលអ្នករំលងប៉ុណ្ណោះទេ ទ្រង់ក៏បានព្យាបាលដល់អ្នកឥតទោសដែលរងទុក្ខដោយអំពើរំលងទាំងនោះផង ។ ពេលជនឥតទោសអនុវត្តសេចក្តីជំនឿលើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ហើយអភ័យទោសដល់ជនរំលងនោះ ពួកគេក៏ត្រូវបានព្យាបាលផងដែរ ។

មានពេលខ្លះយើងម្នាក់ៗ« ត្រូវការការស្រាកស្រាន្តចេញពីអារម្មណ៍ថាមានកំហុសដែលមកពីការធ្វើខុស និងអំពើបាប » ។[15] ពេលយើងប្រែចិត្ត នោះព្រះអង្គសង្គ្រោះនឹងដកយកកំហុសចេញពីព្រលឹងយើង ។

តាមរយៈការលះបង់ដែលធួនរបស់ទ្រង់ បាបយើងនឹងអភ័យទោសឲ្យ ។ ដង្វាយធួនគឺសម្រាប់មនុស្សគ្រប់រូប គ្រប់ពេល មិនថាបាបនោះតូចឬធំ« ស្របតាមលក្ខខណ្ឌនៃការប្រែចិត្ត » ។[16]

ដោយសារសេចក្តីស្រឡាញ់ដ៏គ្មានទីបញ្ចប់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទអញ្ជើញយើងឲ្យប្រែចិត្តដើម្បីយើងនឹងមិនបាច់រងទុក្ខនូវទម្ងន់ដ៏ពេញលេញនៃបាបយើង ៖

« ចូរប្រែចិត្តចុះ បើពុំនោះសោតទេ ...សេចក្តីរងទុក្ខវេទនាទាំងឡាយរបស់អ្នកនឹងឈឺចាប់ណាស់ --- គឺឈឺដល់ណានោះអ្នកមិនដឹងទេ ជ្រួតជ្រាបដល់ណានោះអ្នកមិនដឹងទេ មែនហើយ ធ្ងន់ធ្ងរដល់ណានោះអ្នកមិនដឹងទេ ។ ត្បិតមើលចុះ យើងជាព្រះបានរងទុក្ខនូវការទាំងនេះជំនួសមនុស្សទាំងអស់ ដើម្បីកុំឲ្យគេអាចរងទុក្ខ បើសិនជាពួកគេប្រែចិត្ត ប៉ុន្តែបើសិនជាពួកគេមិនព្រមប្រែចិត្តទេ នោះពួកគេត្រូវរងទុក្ខដូចជាយើងដែរ គឺជាសេចក្តីរងទុក្ខវេទនាដែលបណ្តាលឲ្យយើង គឺជាព្រះដែលមហិមាលើអ្វីៗទាំងអស់ ត្រូវញ័រដោយសារតែការឈឺចាប់ ហើយត្រូវច្រួចលោហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខព្រមទាំងរូបកាយនិងវិញ្ញាណផង » ។[17]

ព្រះអង្គសង្គ្រោះផ្តល់ការព្យាបាលចំពោះអ្នកដែលរងទុក្ខដោយសារអំពើបាប ។ « តើអ្នករាល់គ្នាមិនចង់ត្រឡប់មករកយើង ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់អ្នក ហើយប្រែចិត្តជឿដើម្បីយើងអាចប្រោសអ្នកឲ្យបានជាទេឬ ? »[18]

ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកព្យាបាលដល់ព្រលឹងយើង ។ ក្រៅពីបាបនៃអន្តរធានចេញ នោះគ្មានបាប ឬការរំលង ការឈឺចាប់ ឬទុក្ខព្រួយណាមួយដែលមិនអាចទទួលការអភ័យទោសដោយអំណាចព្យាបាលនៃដង្វាយធួនទ្រង់ឡើយ ។

ពេលយើងមានបាប សាតាំងប្រាប់យើងថាយើងជាមនុស្សបរាជ័យ ។ ផ្ទុយទៅវិញ ព្រះប្រោសលោះរបស់យើងប្រទានការប្រោសលោះដល់មនុស្សទូទៅមិនថាគេធ្វើខុសប៉ុណ្ណាទេ គឺរួមទាំងអ្នកនិងខ្ញុំដែរ ។

ពេលអ្នកពិចារណាពីជីវិតអ្នក តើមានអ្វីដែលអ្នកត្រូវកែប្រែដែរទេ? តើអ្នកធ្លាប់ធ្វើកំហុសដែលចាំបាច់ត្រូវកែតម្រូវដែរទេ?

បើអ្នកកំពុងរងទុក្ខដោយមានកំហុស ឬការស្តាយក្រោយ ភាពល្វីងជូរចត់ ឬ ខឹង ខ្ញុំសូមអញ្ជើញអ្នកឲ្យស្វែងរកវិធីដោះស្រាយ ។ សូមប្រែចិត្ត ហើយជម្រុះបាបអ្នក ។ រួចសុំការអភ័យទោសពីព្រះក្នុងការអធិស្ឋាន ។

សូមស្វែងរកការអភ័យទោសពីអ្នកដែលអ្នកបានធ្វើខុសចំពោះ ។ សូមអភ័យទោសដល់អ្នកដែលធ្វើខុសចំពោះអ្នក ។ សូមអភ័យទោសឲ្យខ្លួនឯង ។

សូមទៅជួបនឹងប៊ីស្សពបើចាំបាច់ ។ គាត់គឺជាអ្នកតំណាងនៃក្តីមេត្តារបស់ព្រះអម្ចាស់។ គាត់នឹងជួយអ្នកពេលអ្នកមានបញ្ហាក្នុងការប្រែក្លាយជាស្អាតស្អំវិញ ។

សូមធ្វើឲ្យខ្លួនអ្នកពោរពេញដោយការអធិស្ឋាន និងការសិក្សាព្រះគម្ពីរ ។ ពេលអ្នកធ្វើបែបនេះ អ្នកនឹងទទួលនូវព្រះចេស្តាលើកតម្កើងពីព្រះវិញ្ញាណ ។ ព្រះអង្គសង្គ្រោះមានបន្ទូលថា ចូរ« ញែកខ្លួនជាបរិសុទ្ធ មែនហើយ ចូរជម្រះចិត្តរបស់អ្នកឲ្យបានបរិសុទ្ធ ហើយលាងដៃរបស់អ្នក ...នៅចំពោះយើងចុះ ប្រយោជន៍ឲ្យយើងអាចធ្វើឲ្យអ្នកបានជ្រះស្អាត » [19]

ពេលយើងត្រូវបានធ្វើឲ្យជ្រះស្អាតតាមរយៈអំណាចនៃដង្វាយធួនរបស់ទ្រង់ ព្រះអង្គសង្គ្រោះនឹងក្លាយជាអ្នកគាំទ្រនឹងព្រះវរបិតា ដោយអង្វរថា « ព្រះវរបិតាអើយ សូមទតមើលការរងទុក្ខទាំងឡាយ និងការសុគតរបស់អ្នកដែលពុំបានធ្វើបាបឡើយ ជាអ្នកដែលព្រះអង្គសព្វព្រះហឫទ័យចុះ សូមទតមើលព្រះលោហិតនៃព្រះរាជបុត្រារបស់ព្រះអង្គដែលបានច្រួច ជាព្រះលោហិតរបស់អ្នកដែលព្រះអង្គបានប្រទានឲ្យ ដើម្បីឲ្យព្រះអង្គបានតម្កើងឡើង ។

« ហេតុដូច្នេះហើយ ឱព្រះវរបិតាអើយ អ្នកផងទាំងនេះជាបងប្អូនរបស់ទូលបង្គំ ដែលជឿដល់ព្រះនាមរបស់ទូលបង្គំ ដើម្បីឲ្យពួកគេអាចមករកទូលបង្គំ ហើយមានជីវិតដ៏នៅអស់កល្បជានិច្ច » ។[20]

យើងម្នាក់ៗបានទទួលនូវអំណោយទាននៃសិទ្ធិជ្រើសរើសខាងសីលធម៌ ។ « មនុស្សលោកមានសេរីភាព ... រើសយកឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះជាអ្នកសង្រ្គោះដ៏ធំរបស់មនុស្សលោកទាំងអស់ ឬក៏រើសយកការជាប់ឃុំឃាំង និងការស្លាប់ ស្របតាម ...អំណាចរបស់អារក្ស » ។[21]

ជាច្រើនឆ្នាំមុន ប្អូនប្រុសខ្ញុំបានអនុវត្តសិទ្ធិជ្រើសរើសគាត់ ពេលគាត់រើសយករចនាបថជីវិតមួយដែលធ្វើឲ្យគាត់ខូចសុខភាព បាត់បង់គ្រួសារ និងសមាជិកភាពរបស់គាត់ក្នុងសាសនាចក្រ ។ ច្រើនឆ្នាំក្រោយមកទៀត គាត់អនុវត្តសិទ្ធិជ្រើសរើសដូចគ្នានេះ ពេលគាត់រើសយកការប្រែចិត្ត ធ្វើឲ្យជីវិតគាត់ស្របតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ហើយពិតជាកើតជាថ្មីតាមរយៈអំណាចនៃដង្វាយធួន ។

ខ្ញុំសូមថ្លែងទីបន្ទាល់ពីអព្ភូតហេតុនៃដង្វាយធួន។ ខ្ញុំបានឃើញពីអំណាចព្យាបាលនេះក្នុងជីវិតប្អូនប្រុសខ្ញុំ ហើយមានអារម្មណ៍នេះក្នុងជីវិតខ្ញុំផ្ទាល់ ។ អំណាចព្យាបាល និងប្រោសលោះនៃដង្វាយធួនគឺមានសម្រាប់យើងគ្រប់គ្នាជានិច្ច ។

ខ្ញុំសូមធ្វើទីបន្ទាល់ថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ --ជាអ្នកព្យាបាលខាងព្រលឹងរបស់យើង។ ខ្ញុំសូមអធិស្ឋានថា យើងគ្រប់គ្នានឹងរើសដើម្បី ឆ្លើយតបនឹងការអញ្ជើញរបស់ព្រះអង្គសង្គ្រោះថា «តើអ្នករាល់គ្នាមិនចង់ត្រឡប់មករកយើង ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់អ្នក ហើយប្រែចិត្តជឿដើម្បីយើងអាចប្រោសអ្នកឲ្យបានជាទេឬ ? »[22] ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. លូកា 15:17 ។
2. គោលលទ្ធិ និង សេចក្តីសញ្ញា 58:42–43 ។
3. សូមមើល នីហ្វៃទី 2 2:25–26 ។
4. សូមមើល អាលម៉ា 34:14 ។
5. អាលម៉ា 42:15 ។
6. សូមមើល អាលម៉ា 34:11 ។
7. សូមមើល អាលម៉ា 34:10 ។
8. សូមមើល អាលម៉ា 22:14 ។
9. ម៉ូសាយ 15:7 ។
10. ម៉ូសាយ 14:10 ។
11. ម៉ូសាយ 3:7 ។
12. អាលម៉ា 7:11 ។
13. អាលម៉ា 7:12 ។
14. ម៉ូសាយ 14:4 ។
15. *ប្រកាសដំណឹងល្អរបស់យើង* ទំព័រ 2 ។
16. គោលលទ្ធិ និង សេចក្តីសញ្ញា 18:12 ។
16. គោលលទ្ធិ និង សេចក្តីសញ្ញា 19:15–18 ។
18. នីហ្វៃទី 3  9:13 ។
19. គោលលទ្ធិ និង សេចក្តីសញ្ញា 88:74 ។
20. គោលលទ្ធិ និង សេចក្តីសញ្ញា 45:4–5 ។
21. នីហ្វៃទី 2  2:27 ។

22. នីហ្វៃទី3  9:13 ។